April 30, 2019

# ចៅក្រមបដិសេធជាលើកទី៣ មិនឲ្យលោកស្រី រ៉ូណា ស្មីត ជួប លោក កឹម សុខា




លោកស្រីរ៉ូណា ស្មីត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ក្នុងអំឡុងទស្សនកិច្ចនៅកម្ពុជា។ @RFI/Phearak

**ដោយ អ៊ឹង ប៊ុនថន rfi 27/04/2019**

ចៅក្រមតុលាការក្រុងភ្នំពេញបានបដិសេធជាថ្មីម្តងទៀត មិនឲ្យអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិប្រចាំកម្ពុជា លោកស្រី រ៉ូណា ស្មីត ជួបលោក កឹម សុខា ឡើយក្នុងដំណើរទស្សនៈកិច្ចរបស់ស្រីមកកាន់កម្ពុជាចាប់ពីដើមសប្តាហ៍ក្រោយនេះ។ ការបដិសេធជាលើកទីពាររបស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដោយសំអាងថា លោក កឹម សុខា កំពុងស្ថិតក្នុងដំណើរការស៊ើបសួរ ដែលច្បាប់ខ្មែរមិនអនុញ្ញាតឲ្យជួបភាគីណាមួយបានឡើយ។

លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានប្រាប់វិទ្យុបារាំងអន្តរជាតិRFIនៅថ្ងៃសៅរ៍ថា ថ្វីត្បិតលោក កឹម សុខា ត្រូវតុលាការដាក់ស្ថិតនៅក្រៅឃុំ តែស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ការស្ថិតកក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ គឺមានភ្ជាប់លក្ខខណ្ឌមួយចំនួនដែលមិនអនុញ្ញាតឲ្យដើរហើរក្រៅទីតាំងដែលតុលាការបានកំណត់ ឬជួបភាគីមួយណាមួយបានឡើយ។

បើតាម លោក ជិន ម៉ាលីន ការដែលចៅក្រមបដិសេធជាលើកទី៣មិនឲ្យលោកស្រី រ៉ូណា ស្មីត ជួប លោក កឹម សុខា គឺដោយសារខ្លាចប៉ះពាល់ដល់ដំណើរការស៊ើបអង្កេតរបស់តុលាការ។

យ៉ាងណាក៏ដោយ លោកស្រី រ៉ូណា ស្មីត បានលើកឡើងថា ការដែលលោកស្រីស្នើសុំជាលើកទី៣ ដើម្បីជួបលោក កឹម សុខាគឺដោយសារតែលោកស្រីបារម្ភពីចំណាត់ការបន្តឃុំខ្លួនបណ្ដោះអាសន្ន និងការចោទប្រកាន់លើអតីតប្រធានគណបក្សប្រឆាំងរូបនេះ។

មកទល់ពេលនេះ គេនៅមិនទាន់ដឹងថា សំណុំរឿងលោក កឹម សុខា នឹងបិទបញ្ចប់ការស៊ើបសួរ ហើយបញ្ជូនទៅជំនុំជម្រះនៅណានោះទេ ខណៈការពន្យាឃុំខ្លួនបណ្ដោះអាសន្នបានអូសបន្លាយ ដល់ជាង១៩ខែហើយ។

សូមជម្រាបថា ក្នុងដំណើរទស្សនកិច្ចរបស់លោកស្រី រ៉ូណា ស្មីត មកកម្ពុជារយៈពេល១១ថ្ងៃ ចាប់ពីថ្ងៃទី២៩ ខែមេសានេះ ដល់ថ្ងៃទី៩ ខែឧសភាខាងមុខ អ្នករាយការណ៍ពិសេសរូបនេះ ផ្ដោតលើបញ្ហាសិទ្ធិមនុស្ស បញ្ហាជម្លោះដីធ្លី រួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

ក្រៅពីសុំជួបលោក កឹម សុខា ដូចរាល់ដងតែមិនបានសម្រេច លោកស្រី ស្មីត គ្រោងជួបមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល តំណាងអង្គការសង្គមស៊ីវិល និងតំណាងសហគមន៍មួយចំនួនទៀតនៅកម្ពុជា៕